# ខួបទី ៥០ របស់អាស៊ាន និងដំណើររួម ជាមួយកម្ពុជា



ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន
រដ្ឋមន្ត្រីការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

## ខួបទី ៥០ របស់អាស៊ាន

ក្នុងឆ្នាំនេះ កម្ពុជាទទួលអំណរសាទររួមគ្នាជាមួយនឹងប្រទេសសមាជិកទាំង១ ០ របស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ក្នុងឱកាសខួបទី ៥០ នៃអង្គការតំបន់នេះ ។

ប្លុកតំបន់មួយនេះបានឆ្លងកាត់ដំណើរដ៏វែងឆ្ងាយចាប់តាំងពីការបង្កើតដំបូងក្នុងឆ្នាំ ១៩៦៧ ប្រឈមមុខនឹងព្យុះ និងបញ្ហាប្រឈមទាំងសេដ្ឋកិច្ចនិងសន្តិសុខ ។ បច្ចុប្បន្ននេះ អាស៊ានត្រូវបានគេចាត់ទុកថាជាអង្គការតំបន់និយម( regionalism ) ដែលជោគជ័យជាងគេមួយ ហើយកំពុងតែដើរតួនាទីស្នូលក្នុងការដាក់ចេញនូវរបៀបវារៈដើម្បីសន្តិភាពនិងវិបុលភាពនៅក្នុងតំបន់ឰក៏ដូចជាសកលលោក ។ អាស៊ានបានបង្ហាញអោយឃើញថា សមាហរណកម្មតំបន់គឺអាចសម្រេចបាន ទោះបីជាមានភាពខុសគ្នារវាងប្រទេសសមាជិកលើកត្តាសាវតារ វប្បធម៌ និងកម្រិតនៃការអភិវឌ្ឍក៏ដោយ ។

ឆ្លងកាត់ការវិវត្តពាក់កណ្តាលសតវត្សរ៍របស់អង្គការតំបន់ដែលបើ កទូលាយមួយនេះ ការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) នៅចុងឆ្នាំ ២០១៥ ត្រូវបានគេចាត់ទុកថាជាសមិទ្ធផលដ៏ធំបំផុតមួយដែលអាស៊ានសម្រេចបាន ។ ផែនការសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ បាននឹងកំពុងផ្តល់ទិសដៅ និងវិធានការយុទ្ធសាស្ត្រទូលំទូលាយដើម្បីឈានទៅសម្រេចបាននូវសហគមន៍មួយដែលមានកម្រិតសមាហរណកម្មខ្ពស់ ទន្ទឹមគ្នានឹងឯកសារគោលផ្សេងទៀតដូចជា ទស្សនៈវិស័យសហគមន៍អាស៊ាន ២០២៥ ផែនការសហគមន៍នយោបាយ-សន្តិសុខ ២០២៥ និងផែនការសហគមន៍សង្គម-វប្បធម៌ ២០២៥ ។

បើយើងចាត់ទុកអាស៊ានដូចជាប្រទេសមួយ បច្ចុប្បន្ននេះ អាស៊ានគឺជាគ្រឹះស្ថានសេដ្ឋកិច្ច និងពាណិជ្ជកម្មសកលដ៏មានឥទ្ធិពលមួយ ដែលឈរលំដាប់ទី ៦ លើពិភពលោកផ្អែកលើទំហំផ.ស.ស. សរុបបញ្ចូលគ្នា ។ នៅឆ្នាំ ២០១៥ ទំហំពាណិជ្ជកម្មសរុបរបស់អាស៊ានឈរលំដាប់ទី ៤ បន្ទាប់ពីចិន អាមេរិក និងអាល្លឺម៉ង់ ។ នៅឆ្នាំដដែលនេះ អាស៊ានបានទទួលការវិនិយោគផ្ទាល់ពីបរទេសសរុប ១២១ប៊ីលានដុល្លារ ស្មើនឹង ៧%នៃចំនួនសរុបក្នុងសកលលោក ។

បើមើលលើកត្តានយោបាយ អាស៊ានគឺជាដែកឆក់ដែលប្រមូលផ្តុំនូវនិម្មាបនកម្មតំបន់ ។

អាស៊ានបានផ្តួចផ្តើម និងថែរក្សាដោយប្រុងប្រយ័ត្ននូវនិម្មាបនកម្មតំបន់សំខាន់ៗជាច្រើន ដែលបានរក្សាអោយតំបន់មានស្ថិរភាព និងវិបុលភាព ជាក់ស្តែង ដូចជាតំបន់ពាណិជ្ជកម្មសេរីអាស៊ានវេទិ កាតំបន់អាស៊ាន អាស៊ានបូកបី កិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិបូក ជាដើម ។

បណ្តាប្រទេសនៅក្នុង និងក្រៅតំបន់អាស៊ីតែងវាយតម្លៃខ្ពស់ និងចាត់ទុកវេទិកានានាដែលដឹកនាំដោយអាស៊ានថាជាវេទិកាដែលអាចជឿទុកចិត្តបានក្នុងការលើកឡើងពីបញ្ហាកង្វល់ និងបញ្ហាប្រឈមរួម ។ នីតិវិធីរបស់អាស៊ានដែលតែងតែស្វែងរកការសន្ទនា ការពិគ្រោះយោបល់ និងការចូលរួម មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់តំបន់ ។ លិខិតូបករណ៍តំបន់សំខាន់ៗដូចជាសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការអាស៊ីអាគ្នេយ៍ (TAC) និងសេចក្តីថ្លែងការណ៍ស្តីពីការប្រតិបត្តិរបស់បណ្តាភាគីនៅសមុទ្រចិនខាងត្បូង (DOC) ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០០២ នៅទីក្រុងភ្នំពេញ ជាដើម ត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយថាជាគោលការណ៍ណែនាំសម្រាប់ទំនាក់ទំនងរវាងរដ្ឋ នឹងរដ្ឋ ។

ភាពជាដៃគូសន្ទនាត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ជាមួយអូស្ត្រាលី កាណាដា ចិន សហភាពអឺរ៉ុប ឥណ្ឌា ជប៉ុន សាធារណរដ្ឋកូរ៉េ ញូវហ្សេលែន រុស្ស៊ី អាមេរិក និងអង្គការសហប្រជាជាតិ ។ មកទល់បច្ចុប្បន្ននេះ មានប្រទេស ៣៥ បូករួមទាំងប្រទេសសមាជិកអាស៊ានបានចូលជារដ្ឋភាគីជាន់ខ្ពស់នៃសន្ធិសញ្ញា TAC ។

## ដំណើររួមរបស់កម្ពុជា

កម្ពុជាបានចូលជាសមាជិកអាស៊ាននៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៩ ហើយយើងជាសមាជិកដែលចូលក្រោយគេបំផុត ។ នេះគឺជាមោទនភាពរបស់យើងដែលបានចូលជាផ្នែកមួយនៃសហគមន៍ និងចូលរួមកសាងសហគមន៍នេះ ក្នុងពាក់កណ្តាលចុងក្រោយនៃប្រវត្តិរបស់អង្គការនេះ ។

សមាហរណកម្មទៅក្នុងសហគមន៍អន្តរជាតិគឺតែងតែជាចំណាប់អារម្មណ៍ជាពិសេសក្នុងគោលនយោបាយការបរទេស និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់កម្ពុជា បន្ទាប់ពីការរងគ្រោះដោយសង្គ្រាមស៊ីវិលដ៏យូរអង្វែង ការដាក់អោយឯកោពីសហគមន៍ - អន្តរជាតិ និងទណ្ឌកម្មសេដ្ឋកិច្ច ។

នៅពេលដែលយើងដាក់បេក្ខភាពជាសមាជិក សម្រាប់កម្ពុជាគឺអាស៊ានមានភាពទាក់ទាញដោយសារការប្តេជ្ញាចិត្តរួម និងការទទួលខុសត្រូវរួមដើម្បីសន្តិភាព ស្ថិរភាព និងវិបុលភាព ដោយផ្អែកលើគោលការណ៍គោរពឯករាជ្យភាព អធិបតេយ្យភាព មិនលូកដៃចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសផ្សេង ការប្រាស្រ័យទាក់ទងដោយស្មើភាពគ្នាដោយគ្មានការដាក់កម្រិត ។ អាស៊ានធ្វើការដោយយោងលើកុងសង់ស៊ុស ទោះបីជាប្រទេសនោះមាន ឬ ក្រ ធំ ឬ តូច ហើយសមាជិកទាំងអស់មានសម្លេងតែមួយស្មើគ្នា ។

បន្ថែមលើគោលការណ៍ខាងលើ សមាហរណកម្មសេដ្ឋ - កិច្ច និងការទូតក៏ជាកត្តាសម្រេចដ៏សំខាន់ដែរ។

កម្ពុជាបានទទួលផលប្រយោជន៍ជាច្រើនពីសហគមន៍ដែលកាន់តែមានកម្រិតសមាហរណកម្មខ្ពស់ ដែលធ្វើអោយលំហូរនៃទំនិញ មូលធន និងប្រជាជនកាន់តែមានភាពងាយស្រួល ។ អាស៊ានបានធ្វើដំណើរលើផ្លូវដ៏ឆ្ងាយបែបនេះបានគឺដោយសារការកសាងសហគមន៍ដោយយោងតាមគោលការណ៍កុងសង់ស៊ុស តាមរយៈការកសាងស្ថាប័នតំបន់ដែលបើកទូលាយ និងវិវត្តបន្តិចម្តងៗ ហើយអនុញ្ញាតអោយមានភាពបត់បែនសម្រាប់សមាជិកក្នុងការអនុវត្តដើម្បីរួមឈានទៅរកគោលដៅរួម ។

ជាមួយនឹងការពង្រឹងភាពតភ្ជាប់ផ្នែករឹង និងផ្នែកទន់ លំហូរនៃប្រជាជនគឺជាឧទាហរណ៍ដ៏សាមញ្ញបំផុតមួយដើម្បីពន្យល់ពីកម្រិតនៃសមាហរណកម្ម ។ ជាក់ស្តែង នៅឆ្នាំ ២០០៨ កម្ពុជាទទួលបានភ្ញៀវទេសចរតែកន្លះលានប៉ុណ្ណោះពីប្រទេសសមាជិកអាស៊ាន ឬ ក៏ស្មើនឹង ២៥% នៃចំនួនទេសចរសរុប ប៉ុន្តែតួលេខនេះបានកើនដល់ ២,១លាននាក់នៅឆ្នាំ ២០១៦ ឬ ក៏ស្មើនឹងជិត៥០%នៃទេសចរសរុប ។ នេះគឺជាការកើនឡើងដល់ទៅ៤ដង ។

សម្រាប់ផ្ទៃក្នុងតំបន់ បើគិតពីយន្តការទីផ្សារ អាស៊ានដើរតួនាទីជាកត្តាតម្រូវការផង ជាកត្តាផ្គត់ផ្គង់ផង ។ នៅឆ្នាំ ២០១៦ ពាណិជ្ជកម្មរវាងប្រទេសសមាជិកអាស៊ានស្មើនឹង ២៣,៤៨% នៃពាណិជ្ជកម្មសរុប ហើយផ្ទៃក្នុងអាស៊ាននៅតែជាទីផ្សារធំបំផុតសម្រាប់អាស៊ាន ។ លំហូរវិនិយោគរវាងប្រទេសអាស៊ានគឺស្មើនឹង ២៤,៧៦% ដែលជាប្រភពវិនិយោគធំបំផុតទី ២ របស់តំបន់ ។

សម្រាប់មជ្ឈដ្ឋានក្រៅតំបន់ ជាមួយនឹងប្រជាជនជាង ៦០០លាននាក់អាស៊ានគឺជាទីផ្សារ និងមូល ដ្ឋានផលិតកម្មដ៏ខ្លាំងមួយ ដែលកាន់តែមានភាពទាក់ទាញ និងប្រកួតប្រជែង ហើយកម្ពុជាក៏បានទទួលផលប្រយោជន៍ ដោយផ្ទាល់ និងដោយប្រយោលពីចំណុចខ្លាំងទាំងនេះដែរ ។

ក្រៅពីសមាហរណកម្មសេដ្ឋកិច្ច កម្ពុជាក៏បានទទួលនូវកាលានុវត្តភាពដើរតួនាទីអន្តរជាតិក្នុងការដាក់ចេញនូវរបៀបវារៈដើម្បីសន្តិភាព និងវិបុលភាពតំបន់ ។ ក្នុងតួនាទីនេះ កម្ពុជាបានចូលរួមចំណែកដល់ការបង្កើនទំនាក់ទំនងរវាងអាស៊ានជាមួយនឹងដៃគូខាងក្រៅ ដែលបានជួយពង្រឹងដល់មជ្ឈភាពរបស់អាស៊ាន និងរក្សាអាស៊ានក្នុងកៅអីអ្នកកាន់ចង្កូតនៃនិម្មាបនកម្មតំបន់ ។

កម្ពុជាបានលើកស្ទួយកិត្យានុភាពអាស៊ាន និងដើរតួនាទីឈានមុខក្នុងកិច្ចខិតខំប្រឹងប្រែងរបស់តំបន់ក្នុងសកម្មភាពកម្ចាត់មីន ។ សេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំអាស៊ានស្តីពីការបង្កើតមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន (ARMAC) ត្រូវបានអនុម័តក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី ២១ នៅឆ្នាំ ២០១២ នៅទីក្រុងភ្នំពេញ ។ មជ្ឈមណ្ឌលនេះបានចាប់ផ្តើមដំណើរការហើយបន្ទាប់ពីការសម្ពោធជាផ្លូវការនៅខែ ឧសភា ឆ្នាំ ២០១៦ ។

កម្ពុជាបានធ្វើជាប្រធានអាស៊ានពីរលើកគឺនៅឆ្នាំ ២០០២ និងឆ្នាំ ២០១២ ។ ឯកសារប្រវត្តិសាស្ត្រដូចជាសេចក្តីថ្លែងការណ៍ DOC ត្រូវបានអនុម័តនៅទីក្រុងភ្នំពេញក្នុងឆ្នាំ ២០០២ ជាមួយនឹងអំណរសាទរយ៉ាងខ្លាំងក្លា ។ ជាមួយនេះ អាស៊ានក៏ត្រូវបានគេធ្វើតេស្ត៍យ៉ាងធ្ងន់ធ្ងរ ដែលនាំអោយអាស៊ានខ្លួនឯងបង្កើនភាពធន់របស់ខ្លួនដល់កម្រិតមួយ ដើម្បីរក្សាជំហរដ៏រឹងប៉ឹង និងការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ដើម្បីរក្សាសន្តិភាព និងស្ថិរភាព ។

កម្ពុជាតែងតែមានសង្គតិភាពជានិច្ចចំពោះភាពអព្យាក្រឹត្យ ព្រោះថានេះគឺជាគោលនយោបាយដែលត្រូវបានចារទុកក្នុងរដ្ឋធម្មនុញ្ញ ហើយក៏ព្រោះតែយើងជឿជាក់ថា សន្តិភាពដែលអាស៊ានបានអភិវឌ្ឍកន្លងមកនេះ អាចសម្រេចបានដោយសារការជឿទុក - ចិត្ត ការសន្ទនា និងការពិគ្រោះយោបល់គ្នាប៉ុណ្ណោះ ពោលគឺមិនមែនកើតឡើងដោយសារការប្រកាន់ប៉ូលនយោបាយ ឬក៏អាក្រក់ជាងនឹងទៅទៀត ដោយសារការបង្កអោយមានភាពរំជើបរំជួលបន្ថែមលើស្ថានភាពតានតឹងដែលកំពុងឡើងកម្តៅនោះទេ ។

ក្របខ័ណ្ឌនៃក្រមប្រតិបត្តិ COC ក៏ជាលទ្ធផលដែលកើតចេញពី "ស្មារតីទីក្រុងបាលី និងសៀមរាប" (Bali-Siem Reap Spirit) ដែលក្នុងស្មារតីនេះ ភាគីពាក់ព័ន្ធឯកភាពអនុវត្តនូវភាពបត់បែន ហើយដាក់បញ្ចូលតែធាតុចូលទាំងឡាយណាដែលបានឯកភាពរួចប៉ុណ្ណោះទៅក្នុងក្របខ័ណ្ឌ COC បន្ទាប់ពីមានកិច្ចប្រជុំនៅទីក្រុងបាលី និងទីក្រុងសៀមរាបនាដើមឆ្នាំ ២០១៧ នេះ ។

កម្ពុជាជឿជាក់ថា នេះគឺជាផលប្រយោជន៍សម្រាប់ទាំងអស់គ្នា នៅពេលដែលអាស៊ានមានស្ថិរភាព និងសន្តិភាព នៅពេលដែលអាស៊ានអាចរក្សាកម្រិតនៃការជឿទុកចិត្តមួយ ជាមួយ នឹងទំនាក់ទំនងប្រកបដោយតុល្យភាពជាមួយនឹងមហាអំណាចតំបន់ដែលពឹងពាក់លើនិម្មាបនកម្មតំបន់របស់អាស៊ាន ដើម្បីរក្សាសន្តិភាព និងស្ថិរភាពដ៏ទូលំទូលាយមួយ ។

កម្ពុជានឹងនៅតែបន្តពួតដៃគ្នាជាមួយនឹងបណ្តាសមាជិកអាស៊ានដទៃទៀត ក្នុងកិច្ចខិតខំប្រឹងប្រែងរួមដើម្បីពង្រឹងសហគមន៍ដែលមានកម្រិតសមាហរណកម្មខ្ពស់ មានភាពធន់ ប្រកបដោយបរិយាប័ន្ន មានការយកចិត្តទុកដាក់ចំពោះប្រជាជន និងការយកប្រជាជនជាស្នូល ដើម្បីជាគុណប្រយោជន៍ដល់សន្តិភាព និងវិបុលភាពរបស់តំបន់ ក៏ដូចជាពិភពលោក ។

ពិតណាស់ថា កិច្ចខិតខំប្រឹងប្រែងទាំងនេះមិនមែនសម្រាប់តែរដ្ឋាភិបាលម្នាក់ឯងនោះទេ ។ គ្រប់គ្នាសុទ្ធតែមានតួនាទីក្នុងការរៀបចំអនាគតរបស់អាស៊ាន ។ ថាតើយើងអាចសម្រេចបាននូវសក្តានុពលរបស់យើងប៉ុណ្ណា ពីសមាហរណកម្មអាស៊ាន

នេះគឺអាស្រ័យលើខ្លួនយើងជាអ្នកសម្រេចចិត្ត ។ នេះគឺអាស្រ័យលើការចូលរួមចំណែករបស់យើង និងការដើរតួនាទីកាន់តែសកម្មក្នុងការរៀបចំរបៀបវារៈរបស់អាស៊ាន ។ ចូរយើងនាំគ្នាអភិវឌ្ឍប្រកប់ដោយស្មារតីខ្ពស់ជាមួយនឹងអាស៊ានដែលបង្កើតឡើងដោយយើងទាំងអស់គ្នា ហើយសម្រាប់យើងទាំងអស់គ្នា ។